# វត្តបទុមវតីរាជវារាម អតីតវត្តខ្ពបតាយ៉ង

ភ្នំពេញៈ វត្តបទុមវតីរាជវារាម ឬ វត្តបទុមវតី ឬ វត្តបទុម ត្រូវបានកសាងឡើងលើកដំបូងនៅក្នុងរជ្ជកាលនៃព្រះបាទ ពញាយ៉ាត និង មានឈ្មោះថា វត្តខ្ពបតាយ៉ង។ បន្ទាប់ពីត្រូវបានបោះបង់ចោលរាប់រយឆ្នាំមក វត្តនេះត្រូវបានកសាងឡើងវិញក្នុងរជ្ជកាលព្រះបាទនរោត្តម ហើយត្រូវ បានព្រះអង្គប្រែឈ្មោះថា វត្តបទុមវតីរាជវារាម។

ក្នុងរជ្ជកាលសម្តេចព្រះបរមរាជាពញាយ៉ាត ទ្រង់បានផ្លាស់ប្តូររាជធានីមកតាំងនៅចតុមុខ គឺភ្នំពេញបច្ចុប្បន្ននេះជាលើកដំបូងនៅថ្ងៃ១៥កើត ខែពិសាខ ឆ្នាំខាលឆស័ក ពុទ្ធសករាជ ១៩៧៨ គ្រិស្តសករាជ ១៤៣៤ ចុល្លសករាជ ៧៩៦។ ក្រៅពីការជួសជុលព្រះវិហារ និងកសាងចេតិយធំនៅលើភ្នំដូនពេញ ទ្រង់បានបញ្ជាឱ្យកសាងវត្តចំនួន៦ទៀត គឺវត្តកោះ១, វត្តលង្កា១, វត្តព្រះពុទ្ធឃោសាចារ្យ១, វត្តពាមផ្លុង១, វត្តឧណ្ណាលោម១ និង វត្តខ្ពបតាយ៉ង១។

វត្តខ្ពបតាយ៉ង ត្រូវបានសាងសង់ឡើងនៅខាងត្បូងព្រះបរមរាជវាំងប្រមាណជា៣០៩ម៉ែត្រ មានបណ្តោយពីលិចទៅកើត២៦០ម៉ែត្រ និងទទឹងពីជើងទៅត្បូង២០២ម៉ែត្រ។ នៅពីមុខវត្តមានដីទំនាប (បឹង) និង ខាងត្បូងវត្តមានដីខ្ពបមួយដែលអ្នកស្រុកតែងហៅថា ខ្ពបតាយ៉ង។ តាយ៉ង ជាឈ្មោះនៃបុរសចំណាស់ម្នាក់ ហើយដោយសេចក្តីជ្រះថ្លាចំពោះព្រះពុទ្ធសាសនា គាត់បានថ្វាយដីខ្ពបរបស់គាត់សម្រាប់ព្រះបាទពញាយ៉ាតសាងសង់វត្ត។ ដើម្បីលើកទឹកចិត្ត និងជាការដឹងគុណដល់គាត់ ទើបព្រះរាជាសព្វព្រះហឫទ័យដាក់ឈ្មោះវត្តនោះថា វត្តខ្ពបតាយ៉ង ព្រោះវត្តនេះសាងសង់ឡើងនៅលើដីខ្ពបរបស់តាយ៉ង។

លុះដល់រជ្ជកាលព្រះបាទនរោត្តម ទ្រង់បានបោះបង់ក្រុងឧដុង្គមានជ័យ មកសាងទីក្រុងភ្នំ ពេញជាគ្រាទី២ ក្នុងឆ្នាំឆ្លូវសប្តស័ក ពុទ្ធសករាជ ២៤០៨ គ្រិស្តសករាជ ១៨៦៥។ ព្រះអង្គបាននិមន្តសម្តេចព្រះសុគន្ធា ធិបតី បញ្ញាសីលោ ប៉ាន ជាសម្តេចព្រះសង្ឃរាជគណៈធម្មយុត្តិក និកាយពីវត្តសាលាគូ ឬវត្តអម្ពិលបី នាក្រុងឧដុង្គមកគង់នៅវត្តខ្ពបតាយ៉ងនេះ ។ ព្រះអង្គក៏បាននិមន្តសម្តេច និល ទៀង ជាសម្តេចព្រះសង្ឃរាជគណៈមហានិកាយពីវត្តពុទ្ធប្រាង្គ ក្រុងឧដុង្គមានជ័យ មកគង់នៅវត្តឧណ្ណាលោម ក្រុងភ្នំពេញ។

គ្រានោះវត្តខ្ពបតាយ៉ង ពុំមានកុដិ សាលា ឬ វិហារដែលជាកេរដំណែលចាស់សេសសល់ទេ សូម្បីតែភិក្ខុសាមណេរមួយអង្គក៏គ្មានផង។ វត្តចាស់នេះបានក្លាយទៅជាព្រៃស្បាតសុទ្ធសាធទៅវិញ ត្បិតត្រូវបានបោះបង់ចោលជាច្រើនរយឆ្នាំ។ ប៉ុន្តែគេដឹងថា ទីនេះជាវត្តបុរាណ ដោយគេបានឃើញមានចារនៅក្នុងព្រះរាជពង្សាវតារផង និង គេបានសង្កេតដីទួលខ្ពស់ជាងគេ ដែលគេអាចសន្និដ្ឋានបានថា ជាទីព្រះវិហារផង ហើយនៅលើដីទួលនោះមានរោងតូចមួយប្រក់ស្លឹក នៅក្នុងរោងនោះមានព្រះដីវ័តូចមួយ

ព្រះអង្គ មានផែនថ្មសន្លឹកសីមាមួយផ្ទាំង និង ថ្មគោលមូលជាច្រើនដុំ។ នៅទិសខាងកើតមុខទួលនោះ មានខ្ពបតូចមួយវែង ហើយនៅទិសខាងត្បូងមានខ្ពបមួយធំជ្រៅដែលអតីតតាយ៉ង បានជីកសម្រាប់យកទឹកស្រោចដំណាំរបស់ គាត់ ។ ឯទឹកនោះមានខ្ចបប្រាំងខ្ចបវស្សា ហើយថ្លាយង់។ អ្នកស្រុកតែងតែអាស្រ័យនឹងទឹកនោះជាប្រក្រតី។

គ្រានោះព្រះបាទសម្ដេចនពោត្តម បានបង្គាប់ឱ្យមេការដឹកជញ្ជូនឈើព្រះរាជទ្រព្យពីក្រុងឧដុង្គមានជ័យ មកសាងកុដិ សាលា និង វិហារ នៅលើដីទួលនោះ ហើយទ្រង់ឱ្យជីកគូ (ស្នាមភ្លោះ) ខាងជើង , ខាងត្បូង , ខាងលិច និងស្តារខ្ពបចាស់របស់តាយ៉ងនោះ ឱ្យជ្រៅថែមទៀត ដើម្បីយកដីចាក់បំពេញទីខ្វង ព្រមទាំងពង្រីកដីទួលនោះឱ្យធំទូលាយជាងមុន ហើយទ្រង់បានបញ្ជាឱ្យដាំឈូកក្នុងគូទាំង៣ជ្រុងនៃវត្តនោះ។

លុះសាងសង់ចប់សព្វគ្រប់ ព្រះអង្គបានប្រារព្ធបុណ្យបញ្ចុះសីមា ឆ្លងព្រះវិហារ កុដិ សាលា និងថាវវត្តនានាក្នុងវត្ត។ ក្នុងពេលនោះ ព្រះអង្គបានប្រែឈ្មោះវត្តនេះថា វត្តបទុមវតីរាជវរារាម ដែលមានន័យថា “អារាមនៃព្រះរាជា ដែលមានផ្កាឈូកព័ទ្ធជារបង” រហូតមកដល់សព្វថ្ងៃ។

សព្វថ្ងៃវត្តនេះភាគច្រើនត្រូវបានគេហៅបំព្រួញមកត្រឹមតែថា វត្តបទុមវតី ឬ វត្តបទុម ប៉ុណ្ណោះ។

ឆ្នាំឆ្លូវនព្វស័ក ពុទ្ធសករាជ ២៥៨០ ព្រះបាទសម្ដេចស៊ីសុវត្ថិ មុនីវង្ស និង សម្ដេចព្រះមង្គល ទេពាចារ្យ បញ្ញាទីបោ ស៊ុក ដែលជាសម្ដេចព្រះសង្ឃរាជគណៈធម្មយុត្តិជំនាន់ទី៣ បានចាត់ការឱ្យរុះរើព្រះវិហារចាស់ចេញ ហើយសាងឡើងជាថ្មីដោយឥដ្ឋ និង ស៊ីម៉ងត៍ជំនួសវិញ ដោយមានប្រជាពុទ្ធបរិស័ទគ្រប់ជាន់ថ្នាក់ចូលរួមផង។

វត្តបទុមវតីរាជវរារាម តាំងពីនៅមានឈ្មោះថា វត្តខ្ពបតាយ៉ង រហូតមកគឺជាវត្តធំនៃព្រះពុទ្ធ សាសនាគណៈធម្មយុត្តិកនិកាយ នៃកម្ពុជទេស ត្បិតជាទីគង់នៅនៃព្រះថេរៈ ដែលមានសម ណស័ក្តិតាំងពីថ្នាក់រាជាគណៈរហូតដល់ថ្នាក់សម្ដេចព្រះសង្ឃរាជ។

ដោយហេតុតែឈ្មោះរបស់វត្តនេះផង ដោយហេតុវត្តនេះត្រូវបានសាងឡើងដោយព្រះរាជាផង និង ដោយសារជាទីគង់នៅនៃព្រះសង្ឃដែលជាសម្ដេចព្រះសង្ឃរាជផង ទើបវត្តនេះត្រូវបានហៅថាជាវត្តស្ដេច។

បន្ទាប់ពីកងទ័ពខ្មែរក្រហមបានជ័យជម្នះលើកងទ័ពសាធារណរដ្ឋខ្មែរ របស់ឧត្តមសេនីយ៍លន់ នល់ និងព្រះអង្គម្ចាស់ ស៊ីសុវត្ថិ សិរិមតៈ ហើយបានកាន់កាប់ប្រទេសកម្ពុជានៅដើមឆ្នាំ១៩៧៥មក វត្តបទុមវតីរាជវរារាម ត្រូវបានបោះបង់ចោលដូចជាវត្តឯទៀតៗទូទាំងប្រទេសដែរ។

១៩៧៩ វត្តនេះត្រូវបានកងទ័ពយនរស់នៅដូចជាបន្ទាយ និងប្រជាជនខ្មែររស់នៅដូចជាផ្ទះនៃគ្រហស្ថធម្មតា។

ឆ្នាំ១៩៨៩ ប្រមុខដឹកនាំខ្មែរ មានសម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ជាដើម បាននិមន្តសម្តេចព្រះពោធិវង្ស នន្ទ ង៉ែត ( បច្ចុប្បន្នជាសម្តេចព្រះមហាសុមេធាធិបតី សម្តេចព្រះសង្ឃនាយកនៃព្រះរាជាណាចក្រកម្ពុជា) ពីវត្តលង្កាកុសមារាម មកគង់នៅដើម្បីដឹកនាំព្រះសង្ឃ និងពុទ្ធបរស័ទ រហូតមក។ ចាប់តាំងពីពេលនោះមក ក៏មានព្រះស្សជាច្រើនមកគង់ស្នាក់នៅរៀនសូត្រ រាប់រយអង្គ។

ដូច្នេះក្នុងសម័យព្រះរាជាណាចក្រកម្ពុជាទី២ នេះ វត្តបទុមវតីរាជវរារាម គឺជាវត្តនៃព្រះសង្ឃគណៈមហានិកាយម្តងវិញ។

នៅឆ្នាំ១៩៩១ ព្រះបាទសម្តេច នរោត្តម សីហនុ បានធ្វើមាតុភូមិនិវត្តន៍ បានសុំឱ្យសម្តេចព្រះសុគន្ធាធិបតី បួរ គ្រី សម្តេចព្រះសង្ឃរាជ គណៈធម្មយុត្តិកនិកាយ មកគង់នៅវត្តបទុមវតីដែរ ប៉ុន្តែមានចំនួនតែមួយកុដិប៉ុណ្ណោះ ។ ទោះយ៉ាងនេះក្តី វត្តបទុមវតីរាជវរារាម នេះនៅតែត្រូវបានគេចាត់ទុកថាជាវត្តនៃគណៈមហានិកាយ ត្បិតក្នុង១ឆ្នាំៗព្រះសង្ឃគណៈមហានិកាយដែលមកគង់នៅសិក្សាបរិយត្តិ មានចាប់ពី៣០០-៤៥០អង្គ។

បច្ចុប្បន្ននេះក្តី វត្តបទុមវតីរាជវរារាម នៅតែជាមណ្ឌលសង្ឃនៃព្រះថេរៈដែលមានសមណៈស័ក្តិធំៗដដែល។

វត្តបទុមវតីរាជវរារាមមិនមែនគ្រាន់តែជាទីសម្រាប់ប្រតិបត្តិធម៌អាថ៌ដែលជាឱវាទនៃព្រះពុទ្ធប៉ុណ្ណោះទេ ប៉ុន្តែក៏ជាជម្រកដ៏ត្រជាក់ក្សាន្តនៃព្រះសង្ឃ និង សិស្ស-និស្សិតមកពីជនបទដើម្បីសិក្សាផងដែរ ៕

ដោយៈ ខឿន សាឃាង

ប្រភពព័ត៌មាន Cambodian Express News

ថ្ងៃព្រហស្បតិ៍ ១៤រោច ថ្ងៃកោរ ខែកត្តិក ឆ្នាំថោះត្រីស័ក ព.ស.២៥៥៥ ត្រូវនឹងថ្ងៃទី២៤ ខែវិច្ឆិកា គ.ស.២០១១

ផ្សាយឡើងវិញដោយ www.templenews.org